# ព្រឹត្តិបត្រ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
*Working Together for Positive Change*

# ការឃ្លាំមើលការអភិវឌ្ឍ និងបញ្ហាដីធ្លីនៅកម្ពុជា








## មាតិកា


- ករណីសិក្សា៖ អំណាចសាលក្រមតុលាការបាននឹងកំពុងរត់ប្រណាំងនឹងអំណាចក្រុមហ៊ុន..១
- ឈប់បណ្តេញប្រជាពលរដ្ឋដោយបង្ខំខណៈពេលដែលសំណុំរឿងក្តីកំពុងដំណើការ ......៤
- ហេតុអ្វីបានជាយើងនៅតែស្ថិតក្នុងចំណោមអ្នកក្រ? តើប្រជាពលរដ្ឋ និងយុវជនអាចធ្វើអ្វីខ្លះដើម្បីកែលម្អ? ......៥
- ការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC) និងការអនុវត្តនៅក្នុងសហាគមន៍ជនជាតិដើមភាគតិច ......១០
- តើទំនប់វារីអគ្គិសនីសំបូរអាចផ្តល់ផលចំណេញច្រើនជាងផលប៉ះពាល់អវិជ្ជមានឬទេ?..១២

# ព្រឹត្តិបត្រការឃ្លាំមើលការអភិវឌ្ឍ និងបញ្ហាដីធ្លីនៅកម្ពុជា

បោះពុម្ពនៅ ខែសីហា ឆ្នាំ២០១៣
ការបោះពុម្ពផ្សាយនេះ បានទទួលការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយនៃ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

## ព័ត៌មានទំនាក់ទំនង

អាសយដ្ឋាន៖ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩ ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉េល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh

## បញ្ជាក់៖

មតិយោបល់ និងសេចក្តីសន្និដ្ឋានទាំងឡាយគឺជាមតិផ្ទាល់របស់អ្នកនិពន្ធ ដោយមិនឆ្លុះបញ្ចាំង
នូវទស្សនៈ និងគោលជំហររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទាំងអស់ឡើយ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**



# អារម្ភកថា

មិត្តអ្នកអានជាទីមេត្រី ព្រឹត្តិបត្រដែលកំពុងស្ថិតក្នុងដៃរបស់អស់លោកអ្នកបាន កើតចេញពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និង ដោយមានការចូលរួមចំណែកពីអង្គការសមាជិកនានារបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និង ជាពិសេសពីបណ្តាញសិទ្ធិដីធ្លី និង លំនៅដ្ឋាន បណ្តាញសិទ្ធិជនជាតិដើមភាគតិច និង ព្រៃឈើ ព្រមទាំងមានការចូលរួមចំណែកយ៉ាងពេញទំហឹងពីសំណាក់អ្នកស្រាវជ្រាវនានា ដែលកំពុងសិក្សាលើការអភិវឌ្ឍអំពីគោលនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងមានសង្ឃឹមថាព្រឹត្តិបត្រនឹងបានចូលរួមចែករំលែកព័ត៌មាន និងផ្តល់ការជជែកពិភាក្សាលើការផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋាភិបាល និង សកម្មភាពអភិវឌ្ឍន៍នានានៅកម្ពុជាដែលអាចរួមចំណែកដល់ការកាត់បន្ថយ ភាពក្រីក្រ និង កិច្ចអភិវឌ្ឍន៍នៅកម្ពុជា ។

គំនិត និងការវិភាគនានា ដែលមាននៅក្នុងអត្ថបទទាំងឡាយគឺជាការយល់ឃើញរបស់អ្នកនិពន្ធសុទ្ធសាធ ហើយការយល់ឃើញនេះ ផ្តើមចេញពីបទពិសោធន៍ និងការរស់នៅជាក់ស្តែងក្នុងបរិបទសង្គមកម្ពុជានាទសវត្សនេះ។

យើងមានសង្ឃឹមថា អត្ថបទទាំងឡាយនេះនឹងជួយអ្នកអានឲ្យអាចធ្វើការឆ្លុះបញ្ចាំងពីបរិបទសង្គម ហើយផ្តើមចេញពីការយល់ឃើញរបស់អ្នកអានម្នាក់ៗ ពួកគេនឹងយកចំណេះដឹងទាំងនេះទៅអនុវត្តក្នុងជីវភាពជាក់ស្តែងប្រចាំថ្ងៃជាក់ជាមិនខាន។

# ករណីសិក្សា៖ អំណាចសាលក្រមតុលាការ បាននឹងកំពុងរត់ប្រណាំងនឹងអំណាចក្រុមហ៊ុន

*អត្ថបទដោយ៖ លោក គិតទូច*
*មន្ត្រីជាន់ខ្ពស់កម្មវិធីច្បាប់ដីធ្លី និងធនធានធម្មជាតិនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍*



*សកម្មភាពបិទផ្លូវជាតិលេខ ២ នៅមុខ សាលាឃុំព្រែកត្រែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល*

កិច្ចអន្តរាគមន៍ពីថ្នាក់លើ បានក្លាយជាវប្បធម៌នៃការប្រើប្រាស់អំណាច តាមផ្លូវច្បាប់នៅកម្ពុជា ជាពិសេសកិច្ចអន្តរាគមន៍លើវិស័យដីធ្លី។ ជាក់ស្តែង នៅចុងខែមីនា ឆ្នាំ២០១៣ មានប្រជាពលរដ្ឋជាង១០០នាក់ ដែលជាភាគីវិវាទជាមួយក្រុមហ៊ុន ហេងអភិវឌ្ឍន៍ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១៥៥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកណ្តាល បានប្រមូលផ្តុំគ្នានៅសួនច្បារវិមានឯករាជ្យបញ្ជូនពាក្យស្នើសុំកិច្ចអន្តរាគមន៍ ពីសំណាក់នាយករដ្ឋមន្ត្រី ដើម្បី ទី១: ជម្រុញឲ្យអាជ្ញាធរមូលដ្ឋានផ្តល់ដីតាមអំណាចសាលក្រមស្ថាពររបស់ សាលាដំបូងខេត្តកណ្តាលលេខ៤០ «វ»ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ និងលេខ១២ «វ»ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ទី២: សម្រួលការចូលកាន់កាប់ជាថ្មីឡើងវិញ និងផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩២គ្រួសារ និងទី៣: បញ្ឈប់ការផ្តល់កងកម្លាំងប្រដាប់អាវុធឲ្យក្រុមហ៊ុន ដើម្បីបញ្ចៀសការប្រើកម្លាំងសាធារណៈខុសច្បាប់[១] ។ សាលក្រមទាំងពីរនេះ ក៏បានទទួលស្គាល់ដោយព្រមគ្នានូវប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីចំនួន៤២

[១] សាលកម្រស្ថាពរលេខ ៤០ «វ» សម្រេចឡើងតាមរយៈស្មារតីនៃសវនាការជាសាធារណៈ នៅថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០០៦ (សវនាការលើកទីមួយ) ដោយបានសម្រេចជាឧឡាប្វកនូវចំណុចជាគន្លឹះពីរ ពោលគឺ «ទទួលស្គាល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុរបស់ក្រុមហ៊ុន ហេង អភិវឌ្ឍន៍ចំនួន៤២ប័ណ្ណ ទុកជាត្រឹមត្រូវតាមច្បាប់ គិតពីថ្ងៃប្រកាសសាលក្រមស្ថាពរតទៅ» និង«ដីពុំមានប័ណ្ណសម្គាល់សិទ្ធិដែលអ្នកកំពុងកាន់កាប់សព្វថ្ងៃត្រូវរក្សាស្ថានភាពដើមដដែល»។ គ្រានោះ ភាគីប្រជាពលរដ្ឋគឺមានតំណាង ៥៨ គ្រួសារ ចូលរួមសវនាការ។ដោយសារអវត្តមានរបស់តំណាងប្រជាពលរដ្ឋមួយក្រុមទៀត តំណាងឲ្យ ២៣៤ គ្រួសារ ដែលមានទីលំនៅនៅឃុំជើងកើប និងឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលនាឱកាសនៃសវនាការសាធារណៈលើកទីមួយដូច្នេះ ពួកគាត់ក៏សម្រេចធ្វើការ «ប្តឹងទាស់» ទៅនឹងសាលក្រមលេខ ៤០ «វ»។ក្រោយមក គឺនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ សាលាដំបូងខេត្តកណ្តាល ក៏បានធ្វើការបើកការជំនុំជម្រះម្តងទៀត និងបានសម្រេចចេញសាលក្រមលេខ ១២«វ» ជាថ្មីមួយទៀតដោយបានសម្រេច ថា៖ «តម្កល់សាលក្រមលេខ៤០«វ» ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ ឲ្យនៅពេញលេញដដែល» ហើយបន្ថែមទៅលើចំណុចដីដែលស្ថិតនៅក្រៅពីប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលបានសម្រេចនៅក្នុងសាលក្រមលេខ៤០«វ» ហើយដែលមានទីតាំងស្ថិតនៅឃុំជើងកើប និងឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានប្រជាពលរដ្ឋ២៣៤គ្រួសារ កំពុងកាន់កាប់ និងគ្រប់គ្រង «រក្សានៅដដែលគិតពីថ្ងៃសាលក្រមស្ថាពរនេះតទៅ»។ ដោយឡែក តាមពាក្យបណ្តឹងរបស់តំណាងប្រជាពលរដ្ឋម្នាក់ សុំឲ្យអង្គទូតសំខាន់ៗ តួយ៉ាងទូតអាឡឺម៉ង់ និងអង់គ្លេស ជាដើម បានបញ្ជាក់ថា៖ «តាមពិតទៅតំបន់របស់ពួកគាត់ មានទំហំដល់ទៅ ៤៥០ ហិកតា ឯណោះ។ ជាអកុសល ក្បាលដីរបស់គ្រួសារ ៩៦ នៅក្នុងចំណោមគ្រួសារសរុបទាំង ២៩២ គឺខាកខានពុំបានបញ្ជាក់ក្នុងអង្គសវនាការសាធារណៈលើកទី ២ (សាលក្រមស្ថាពរលេខ ១២ «វ»)។ ហើយជំហរនៃការ ទាមទារជាសាធារណៈសព្វថ្ងៃ គឺចំនួន «៤៥០ ហិកតា សម្រាប់ ២៩២ គ្រួសារ» ប៉ុន្តែ ពុំមែន ២៣៩ ដូចក្នុងសាលក្រមស្ថាពរលេខ ៤០ «វ» (ជាង ១៣៨ ហិកតា ៤៣ អា) និងលេខ ១២ «វ» (១០១ ហិកតា ៨០ អា) នោះទេ។ ដោយឡែក តាមពាក្យបណ្តឹងរបស់តំណាងប្រជាពលរដ្ឋម្នាក់ សុំឲ្យអង្គទូតសំខាន់ៗ តួយ៉ាងទូតអាឡឺម៉ង់ និងអង់គ្លេស ជាដើម បានបញ្ជាក់ថា៖ «តាមពិតទៅតំបន់របស់ពួកគាត់ មានទំហំដល់ទៅ ៤៥០ ហិកតា ឯណោះ។ ជាអកុសល ក្បាលដីរបស់គ្រួសារ ៩៦ នៅក្នុងចំណោមគ្រួសារសរុបទាំង ២៩២ គឺខាកខានពុំបានបញ្ជាក់ក្នុងអង្គសវនាការសាធារណៈលើកទី ២ (សាលក្រមស្ថាពរលេខ ១២ «វ»)។ ហើយជំហរនៃការ ទាមទារជាសាធារណៈសព្វថ្ងៃ «៤៥០ ហិកតា សម្រាប់ ២៩២ គ្រួសារ» ប៉ុន្តែ ពុំមែន ២៣៩ ដូចក្នុងសាលក្រមស្ថាពរលេខ ៤០ «វ» (ជាង ១៣៨ ហិកតា ៤៣ អា) និងលេខ ១២ «វ» (១០១ ហិកតា ៨០ អា) នោះទេ។



*សកម្មភាពឈូសឆាយដីសហគមន៍ដោយ ក្រុមហ៊ុនហេងអភិវឌ្ឍន៍*

របស់ក្រុមហ៊ុនហេងអភិវឌ្ឍន៍ ព្រមទាំងសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីរបស់ប្រជាពលរដ្ឋ ២៩២គ្រួសារដែលបានកាន់កាប់ និងប្រើប្រាស់ដីធ្លីជាង២៣៩ហិកតា[២] ដោយសន្តិភាពកន្លងមក។ តាមការផ្ទៀងផ្ទាត់និយាមការណ៍ និងចំណុចចង្អុលទីតាំងរបស់ប័ណ្ណទាំង៤២ របស់ក្រុមហ៊ុនឃើញថាមានតែ ៨ប័ណ្ណ គឺស្មើនឹង៣២ហិកតាតែប៉ុណ្ណោះ ដែលមានទីតាំងជាប់គ្នា នឹងតំបន់របស់ប្រជាពលរដ្ឋ ដែលទទួលបានសិទ្ធិបន្តកាន់កាប់ដោយស្របច្បាប់តាមអំណាចនៃសាលក្រមខាងដើម។ សាលក្រមស្ថាពរទាំងពីរ ត្រូវបានអនុវត្តតាមនីតិវិធីច្បាប់ ដោយតំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាលចំនួនបីលើកជាបន្តបន្ទាប់នាចុងខែកក្កដា ខែសីហា ឆ្នាំ២០០៧និងដើមខែមេសា ឆ្នាំ២០០៨ ដោយមានគូភាគីទំនាស់ចូលរួម និងឯកភាពលើដំណើរការអនុវត្តព្រមទាំងមានតំណាងអាជ្ញាធររដ្ឋបាល ថ្នាក់ស្រុក និងឃុំ ជំនាញខាងភូមិបាល និងកងកម្លាំងនគរបាល និងរាជអាវុធហត្ថ ចូលរួមទៀតផង។

តាមពិតទៅសាលក្រមទាំងពីរ ខាងលើត្រូវបានផ្តើមចេញពីបណ្តឹងរបស់នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៥ ដោយលោកស្រីសំអាងថា ក្រុមពលរដ្ឋ២៩២គ្រួសារ បានសង់រោង និងផ្ទះ ព្រមទាំងដាំដំណាំនៅលើដីក្រុមហ៊ុន ដែលមាន១៦ប័ណ្ណ នៅឃុំព្រែកស្ដែង១៨ប័ណ្ណនៅឃុំបឹងខ្យាង និង ៨ប័ណ្ណផ្សេងទៀត នៅឃុំកណ្តោក (ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល)។ចំណែកភាគីប្រជាពលរដ្ឋ២៩២គ្រួសារបានអះអាងថា ពួកគាត់ ៥៨គ្រួសារ មកពីសង្កាត់ព្រែកហូរក្រុងតាខ្មៅ ១៩៣គ្រួសារមកពីឃុំកណ្តោក និង៤១គ្រួសារមកពីឃុំជើងកើប ស្រុកកណ្តាលស្ទឹង ធ្លាប់បានបង្កបង្កើនផលជាលក្ខណៈក្រុមសាមគ្គី តាំងពីសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជាផងនោះ បានមកកាន់កាប់ដីធ្លី និងប្រកបរបរកសិកម្មចិញ្ចឹមជីវិតលើផ្ទៃដីប្រមាណ ៤៥០ហិកតា នៅចំណុចទំនប់៩៤ និងប្រឡាយ៦៣ (តំបន់ទំនាស់) ឡើងវិញ រវាងឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៩០រហូតមក។ កំឡុងពេលនោះផ្ទៃដីទាំងមូលពោរពេញទៅដោយព្រៃ និងពុំមានអ្នកកាន់កាប់ឡើយប្រជាពលរដ្ឋបានធ្វើស្រែប្រាំង ដាំឈូក និងបន្លែផ្សេងៗតាមតម្រូវការ។

ជាងនេះទៅទៀត ដើម្បីជាគុណប្រយោជន៍ដល់ការប្រតិបត្តិពុទ្ធសាសនា អាស្រមមួយមានឈ្មោះថា «អាស្រមតាម៉ក់» ត្រូវបានកសាងឡើងក្នុងកំឡុងឆ្នាំ២០០០ផងដែរ។ បើទោះជាប្រជាពលរដ្ឋ២៩២គ្រួសារ មានឧត្តមភាពតាមផ្លូវច្បាប់ ដើម្បីបន្តកាន់កាប់ដីធ្លីប្រមាណ៤៥០ហិកតា ស្របតាមសាលក្រមលេខ៤០«រ»និងលេខ១២«រ» ក៏ដោយ ក៏ភាគីក្រុមហ៊ុនបានប្រើប្រាស់កម្លាំងកងរាជអាវុធហត្ថ និងនគរបាលក្នុងតំបន់ដើម្បីការពារការឈូសឆាយ និងត្រួតត្រាលដីទំនាស់ទាំងស្រុង ទាំងដីស្របច្បាប់នឹងដីអាស្រមពុទ្ធសាសនា ដែលមានព្រះសង្ឃបីអង្គគង់ចាំព្រះវស្សារផង។ ភាគីក្រុមហ៊ុនពុំបានខ្វាយខ្វល់ទៅនឹងឥទ្ធិពល ឬផលវិបាកផ្លូវច្បាប់ទេ។

ជាក់ស្តែងនៅថ្ងៃទី១៦ និង១៧ ខែមករា ឆ្នាំ២០០៩ ភាគីក្រុមហ៊ុន បានដាក់ពង្រាយគ្រឿងចក្រចំនួន១២គ្រឿង និងកងកម្លាំងអាវុធហត្ថនគរបាលថ្នាក់ស្រុកនិងខេត្តប្រមាណជា២០០នាក់ឲ្យប្រចាំការ និងការពារសកម្មភាពឈូសឆាយដីដោយពុំព្រមស្តាប់អំណះអំណាងផ្លូវច្បាប់ និងការអង្វកររបស់ប្រជាពលរដ្ឋឡើយ។ មិនតែប៉ុណ្ណោះកងកម្លាំងទាំងនេះ បានធ្វើការបាញ់រះមកលើហ្វូងប្រជាពលរដ្ឋ បណ្តាលឲ្យមនុស្ស២នាក់ ទទួលរងរបួសធ្ងន់ត្រង់កែងដៃស្តាំង ធ្លាយពោះខាងស្តាំ និងរបួសត្រង់ភ្លៅខាងស្តាំ។ សព្វថ្ងៃនេះជនរងគ្រោះម្នាក់បានពិការដៃទាំងស្រុង។ ប្រជាពលរដ្ឋទទួលការគម្រាមកំហែង ថានឹងត្រូវចាប់ដាក់គុក

[២] ដោយឡែក តាមពាក្យបណ្តឹងរបស់តំណាងប្រជាពលរដ្ឋម្នាក់ សុំឲ្យអង្គទូតសំខាន់ៗ តួយ៉ាងទូតអាឡឺម៉ង់ និងអង់គ្លេស ជាដើម បានបញ្ជាក់ថា៖ «តាមពិតទៅតំបន់របស់ពួកគាត់ មានទំហំដល់ទៅ ៤៥០ ហិកតា ឯណោះ។ ជាអកុសល ក្បាលដីរបស់គ្រួសារ ៩៦ នៅក្នុងចំណោមគ្រួសារសរុបទាំង ២៩២ គឺខាកខានពុំបានបញ្ជាក់ក្នុងអង្គសវនាការសាធារណៈលើកទី ២ (សាលក្រមស្ថាពរលេខ ១២ «រ»)។ ហើយជំហរនៃការ ទាមទារជាសាធារណៈសព្វថ្ងៃ គឺចំនួន «៤៥០ ហិកតា សម្រាប់ ២៩២ គ្រួសារ» ប៉ុន្តែ ពុំមែន ២៣៩ ដូចក្នុងសាលក្រមស្ថាពរលេខ ៤០ «រ» (ជាង ១៣៨ ហិកតា ៤៣ អា) និងលេខ ១២ «រ» (១០១ ហិកតា ៨០ អា) នោះទេ។



*សកម្មភាពតវ៉ានៅមុខសាលាដំបូងខេត្តកណ្តាល ឲ្យដោះលែងជនបង្គោសហគមន៍ដែលត្រូវបាន ឃុំខ្លួនជាបណ្តោះអាសន្ន*

ប្រសិនបើ នៅតែបន្តការតវ៉ាដីធ្លីតំបន់ទំនាស់នេះទៀត។

នៅចុងឆ្នាំ២០០៩ ខាងក្រុមហ៊ុន ក៏បានប្តឹងចោទតំណាងប្រជាពលរដ្ឋ ៣នាក់ពីបទ «បានប្រព្រឹត្តិបទ ល្មើសរំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ និងប្រើអំពើហិង្សា» ពីព្រោះពួកគាត់ពុំព្រមបញ្ឈប់ការប្តឹងតវ៉ា និងស្វះស្វែងរកកិច្ចគាំទ្រពីស្ថាប័នពាក់ព័ន្ធ។ព្រមគ្នានេះដែរស្ថាប័នអយ្យការអមសាលាដំបូងខេត្តកណ្តាល និងចៅក្រមស៊ើបសួរបានចាត់ការយ៉ាងសកម្មលើសំណុំរឿងក្តីព្រហ្មទណ្ឌមួយនេះជាបន្តបន្ទាប់ ចាប់ពីដើមឆ្នាំ២០១០ ដល់ចុងឆ្នាំ២០១០។ តំណាងប្រជាពលរដ្ឋម្នាក់ក្នុងចំណោម៣នាក់ខាងដើម ត្រូវបានចាប់ដាក់ពន្ធនាគារ ក្រោយពីមានហេតុការណ៍នៃការមិនព្រមទទួលសំណើចចារទិញផ្ទះ តាមសំណើតម្លៃទាបជាងទីផ្សារ ពីសំណាក់ភ្នាក់ងាររបស់ក្រុមហ៊ុន។ សមាគមអាដហុកបានផ្តល់មេធាវីដើម្បីការពារសិទ្ធិតាមផ្លូវច្បាប់។

ជាងនេះទៅទៀត នៅចុងឆ្នាំ២០១០ ប្រជាពលរដ្ឋពាក់ព័ន្ធទាំងបីឃុំ (កណ្តោក ជើងកើប និងព្រែកហូរ) និងមានព្រះសង្ឃចូលរួមផងនោះ បាននាំគ្នាកាន់បដាស្រែកទាមទារ និងចែកញ្ញាត្តិដែលខ្លឹមសារថា «សូមអំពាវនាវឲ្យដោះស្រាយទំនាស់ដីធ្លី» និងសូមបញ្ឈប់ការចោទប្រកាន់តំណាងប្រជាពលរដ្ឋក្នុងរឿងទំនាស់ដីធ្លី»។

ប្រជាពលរដ្ឋ បានសំណូមពរប្រមុខរាជរដ្ឋាភិបាល តំណាងស្ថាប័នជាតិគ្រប់ជាន់ថ្នាក់ និងតំណាងអង្គទូតប្រចាំនៅកម្ពុជា ឲ្យជួយបំពេញនូវសំណូមពរមាន៥ចំណុច ទី១: សូមដោះស្រាយបញ្ហាទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃ អូសបន្លាយពីឆ្នាំ២០០៥មកនេះ ទី២: សូមជួយអន្តរាគមន៍បញ្ឈប់ការឈូសឆាយវត្តទួលតាម៉ក់ ដើម្បីទុកជាទីសក្ការៈបូជាតាមព្រះពុទ្ធសាសនា ទី៣:សូមជួយអន្តរាគមន៍បញ្ឈប់ការចោទប្រកាន់តាមចាប់ខ្លួនតំណាងប្រជាពលរដ្ឋ ទី៤: សូមឲ្យគ្រប់ស្ថាប័នជាតិជួយអន្តរាគមន៍ឲ្យមានការអនុវត្តន៍តាមសាលក្រមរដ្ឋប្បវេណីលេខ៤០«វ»និងលេខ១១២«វ» និង ទី៥:សូមឲ្យរាជរដ្ឋាភិបាលបញ្ឈប់ការផ្តល់កម្លាំងប្រដាប់អាវុធឲ្យក្រុមហ៊ុនឯកជនបង្កឲ្យមានភាពភ័យខ្លាច ប្រើអំពើហិង្សា ការគម្រាមកំហែងនិងបាញ់រះលើហ្វូងប្រជាពលរដ្ឋ។ក្រោយពីមានការប្រមូលផ្តុំនិង លើកបដា សាលាដំបូងខេត្តកណ្តាល បានឲ្យតំណាងប្រជាពលរដ្ឋចូលជួបចៅក្រមកាន់សំណុំរឿង ហើយបន្ទាប់ពីមានអន្តរាគមន៍តាមផ្លូវច្បាប់ពីសំណាក់មេធាវីជនជាប់ឃុំត្រូវបានដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន។

ចំពោះសំណុំរឿងមួយនេះ មានសំណើសុំកិច្ចអន្តរាគមន៍ដាច់ដោយឡែកពីគ្នាជាច្រើន ដូចជាពីក្រសួងមហាផ្ទៃ នៅចុងឆ្នាំ២០០៧ ខុទ្ទកាល័យប្រមុខរាជរដ្ឋាភិបាល នៅដើមឆ្នាំ២០០៨ ក្រសួងយុត្តិធម៌ នៅពាក់កណ្តាលឆ្នាំ២០០៩ សម្តេចប្រធានព្រឹទ្ធសភា នៅដើមឆ្នាំ២០០៩ និងអាជ្ញាធរជាតិដោះស្រាយ ទំនាស់ដីធ្លីនៅចុងឆ្នាំ២០០៩ ដែលបានទទួលលិខិតសំណូមពរដោយផ្ទាល់ពីតំណាងប្រជាពលរដ្ឋ ដើម្បីឲ្យអាជ្ញាមូលដ្ឋានអនុវត្តសាលក្រមស្តាពរលេខ៤០«វ» និងលេខ១១២«វ»។ នៅមានលិខិតមួយច្បាប់ជូនអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីបានស្នើឲ្យថ្នាក់ខេត្តពិនិត្យ និងដោះស្រាយ (សំណូមពររបស់ប្រជាពលរដ្ឋ ២៩២ គ្រួសារ) ឲ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីសម្រួលការលំបាក និងទុកឱកាសជូនសម្តេចសម្រេចភារៈកិច្ចធំៗសម្រាប់ប្រទេសជាតិ» ប៉ុន្តែរហូតមកឆ្នាំ២០១៣សំណុំរឿងនេះ មិនទាន់ត្រូវបានដោះស្រាយនៅឡើយ។

នេះជារឿងមួយដែលត្រូវពិចារណា ថាតើគួរបន្តវប្បធម៌នៃកិច្ចអន្តរាគមន៍ ខ្វែងខ្វាត់បែបនេះតទៅទៀត ឬគប្បីបណ្តុះវប្បធម៌ឲ្យមានការអនុវត្តច្បាប់មានគណនេយ្យភាពលើតួនាទី និងភារកិច្ចរបស់ខ្លួន?។ ករណីទំនាស់ដីធ្លីខាងលើនេះសរឲ្យឃើញនូវប្រៀបខ្លាំងនៃអំណាចរបស់ក្រុមហ៊ុន ដែលមានសភាពលើសលុបលើអំណាចសាលក្រម។

# ឈប់បណ្តេញប្រជាពលរដ្ឋដោយបង្ខំ ខណៈពេលដែលសំណុំរឿងក្តីកំពុងដំណើការ

*អត្ថបទដោយ៖ លោក សុខ សុខុម*
*ប្រធានសាខាអង្គការស្រាវជ្រាវជាតិកម្ពុជាប្រចាំខេត្តព្រះសីហនុ*

នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ បានប្រកាសឲ្យប្រគល់ដី និង សាងសង់លំនៅដ្ឋានជូនដល់ប្រជាពលរដ្ឋចំនួន ៤៩គ្រួសារនៅពយចំរាំងឃុំកែវផុសស្រុកស្ទឹងហាវ ខេត្តព្រះសីហនុបន្ទាប់ពីមានការឈូសឆាយកម្ទេច ផ្ទះសម្បែងរបស់ពួក គាត់អស់ចំនួន១៧ខ្នង ដោយ នាយកក្រុមហ៊ុនស្រាបៀរលីអូ ក្រោមការដឹកនាំពី មន្ត្រីសាលាដំបូងខេត្តព្រះសីហនុអនុវត្តតាមសាល ក្រមរដ្ឋប្បវេណីលេខ០៤"ក១"ចុះថ្ងៃទី០៦ខែមេសា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលសំណុំរឿងនេះ កំពុងជាប់នីតិវិធីនៅសាលា ឧទ្ធរណ៍នៅឡើយ។ សំណុំរឿងវិវាទដីធ្លីនេះបាន កើតឡើងនៅក្នុងឆ្នាំ២០០៥។

សម្តេច ហ៊ុន សែន ក៏បានប្រកាសលុប ចោលនូវសេចក្តីជូនដំណឹងលេខ៦៦៩ចុះថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ទាក់ទងនឹងទំនាស់ដីធ្លីនៅចំនុចពយចំរាំង ឃុំ កែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នេះ ផងដែរ។ កិច្ចអន្តរាគមន៍នេះ ត្រូវបានទទួលការ គាំទ្រពីប្រជាពលរដ្ឋក៏ដូចជាមជ្ឈដ្ឋានសាធារណៈ។

ទោះជាយ៉ាងនេះក្តី នៅតាមបណ្តាខេត្ត ផ្សេងៗទៀត នៅតែមានសកម្មភាពរំលោភបំពាន ដីធ្លី និង ការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ ខ្លាំងក្លានៅឡើយ តាមរយៈការផ្តល់សម្បទាន ដីសេដ្ឋកិច្ចនិងកិច្ចអភិវឌ្ឍន៍នានាហើយជានិច្ចកាល ការដោះស្រាយជូនប្រជាពលរដ្ឋទំនាស់ទាំងនោះ នៅមិនទាន់មានប្រសិទ្ធភាព និងតម្លាភាពនៅឡើយ។ ប្រជាពលរដ្ឋរងគ្រោះនៅតែទទូចអង្វរ និងសំណូមពរ ទៅប្រមុខរាជរដ្ឋាភិបាលឲ្យមានវិធានការតាមផ្លូវច្បាប់ ដើម្បីអនុវត្តលើមន្ត្រីអ្នកច្បាប់តែមិនគោរពច្បាប់ ។

សាលាដំបូងខេត្តព្រះសីហនុ យកសាល ក្រមរដ្ឋប្បវេណីលេខ០៤ "ក១" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ស្ថិតក្នុងសំនុំរឿងរដ្ឋប្បវេណី លេខ២០៣ ចុះថ្ងៃទី០៧ខែធ្នូឆ្នាំ២០១១ មកអនុវត្ត ជាបណ្តោះអាសន្ននិងចេញលិខិតជូនដំណឹងពីការ អនុវត្តន៍សាលក្រមបណ្តោះអាសន្ន លេខ២៦៣ សជណ១៣ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តព្រះសីហនុ ឃើញថាផ្ទុយ នឹងសេចក្តីណែនាំរបស់តុលាការកំពូល លេខ ១១៤/០៨ តកក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨ និងបទបញ្ញត្តិច្បាប់ ដែលបានកំណត់នៅក្នុងក្រម និតិវិធីរដ្ឋប្បវេណី។

តើអ្នកណាទទួលខុសត្រូវចំពោះផលវិបាក ដែលកើតឡើងចំពោះជនរងគ្រោះ? តើសាលា ឧទ្ធរណ៍ដំណើការលើសំណុំរឿងក្តីនេះ យ៉ាងដូច ម្តេចបើកម្មវត្ថុវិវាទចំបង ត្រូវបានបំផ្លាញ និង



*រូបភាពសកម្មភាពអនុវត្តសាលក្រមរបស់សាលាដំបូងខេត្តព្រះសីហនុ នៅចំនុចពយចំរាំង ស្រុកស្ទឹងហាវ ឃុំកែវផុស*

បាត់បង់អស់ទៅហើយនោះ?។ ចុះបើភាគីខាងប្រជាពលរដ្ឋ ត្រូវបានសាលាឧទ្ធរណ៍សម្រេចឲ្យឈ្នះក្តីវិញនោះ តើការខូចខាតផ្ទះសម្បែង សម្ភារៈ និងផលដំណាំទាំងនេះ តើអ្នកណាជាអ្នកទទួលខុសត្រូវ?។ ការអនុវត្តសាលក្រមបណ្តោះអាសន្ននេះ គឺជាការបំបាត់ភស្តុតាងចោលដើម្បីកុំឲ្យពលរដ្ឋមានលទ្ធភាពតវ៉ានៅសាលាឧទ្ធរណ៍ជាបន្តទៀត។ តើចំនុចត្រង់ណាទៅដែលថាជាការអនុវត្តច្បាប់របស់អ្នកអនុវត្តច្បាប់ បើសំណុំរឿងក្តីកំពុងត្រូវបានដំណើការនៅសាលាឧទ្ធរណ៍ បែរជាសាលាដំបូង ចុះមកអនុវត្តសាលក្រមជាបណ្តោះអាសន្ន ហើយបានបំផ្លាញផ្ទះសម្បែង ដែលជាកម្មវត្ថុនៃបណ្តឹងដែលកំពុងដំណើការក្តីនៅសាលាឧទ្ធរណ៍ទៀតផងនោះ។

ករណីដូចគ្នានេះដែរ ក៏ត្រូវបានកើតឡើងចំពោះប្រជាពលរដ្ឋនៅភូមិ ៣-ចំការចេក ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលសាលាដំបូងខេត្តកំពង់ស្ពឺ ចុះអនុវត្តសាលដីកា សាលាកំពូល ខណៈពេលដែលសាលាកំពូលបានបង្វិលសំណុំរឿងមកសាលាឧទ្ធរណ៍ ដើម្បីឲ្យធ្វើការសម្រេចឡើងវិញ។ ជាងនេះទៅទៀត សាលាឧទ្ធរណ៍បានកំពុងដំណើការក្តី ដោយបានចេញដីកាកោះ បង្គាប់ឲ្យតំណាងប្រជាពលរដ្ឋចូលខ្លួនបំភ្លឺនៅតុលាការ ប៉ុន្តែជាអកុសសមិនទាន់បានចូលខ្លួនបំភ្លឺនៅ សាលាឧទ្ធរណ៍តាមដីកាបង្គាប់ផងស្រាប់តែសាលាដំបូង ចុះអនុវត្តសាលដីកាបណ្តេញប្រជាពលរដ្ឋដោយបង្ខំ រហូតមានអំពើហិង្សា មានការបាញ់គំរាម និង ព្រះរាជ្វារងដែលដឹកនាំអនុវត្តដីកានោះ បានប្តឹងប្រជាពលរដ្ឋពីបទរារាំងទៀតផង។

សកម្មភាពនៃការចុះបណ្តេញ ប្រជាពលរដ្ឋដោយបង្ខំ និងការបំផ្លាញទ្រព្យសម្បត្តិ ផ្ទះសម្បែង ក្នុងខណៈពេល ដែលសំណុំរឿងកំពុងដំណើការក្តីនេះ ជាទង្វើមួយដែលមិនអាចទទួលយកបានឡើយ ហើយក៏ជាសក្ខីភាពមួយបង្ហាញពីការប្រើប្រាស់អំណាច ដោយបំពានច្បាប់ គាបសង្កត់ប្រជាពលរដ្ឋក្រីក្រ និងបង្ហាញពីភាពកំសោយនៃការអនុវត្តច្បាប់ នៅក្នុងប្រទេស ដែលអ្នកមានអំណាច និងអ្នកអនុវត្តច្បាប់មួយចំនួន ដើរបង្កព្យុះភ្លៀងតាមអំពើចិត្ត បង្កទុក្ខលំបាកដល់ប្រជាពលរដ្ឋ និងធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល និងស្ថាបន័របស់រដ្ឋ និងប្រទេសទាំងមូលទៀតផង។

# ហេតុអ្វីបានជាយើងនៅតែស្ថិតក្នុងចំណោមអ្នកក្រ? តើប្រជាពលរដ្ឋ និងយុវជនអាចធ្វើអ្វីខ្លះដើម្បីកែលម្អ?

*ដោយ ណារ៉ា សុខហេម៉ា*[១]

នៅថ្នាក់បឋមសិក្សា កុមារកម្ពុជាទន្ទេញមេរៀនរាល់ថ្ងៃថាប្រទេសកម្ពុជា មានស្ថានភាពភូមិសាស្ត្រនិងធម្មជាតិដ៏ល្អ សម្រាប់ការរស់នៅ ផលិតកម្មកសិកម្ម ទេសចរណ៍ ក៏ដូចជាធនធានធម្មជាតិដ៏សម្បូណ៌បែប ដែលអាចធ្វើឲ្យយើងក្លាយជាអ្នកមាន។ នៅពេលយើងធំដឹងក្តី យើងចាប់ផ្តើមសួរថា "បើយើងបាន និងកំពុងតែដើរលើដីសុវណ្ណភូមិប្រេងកាត ធនធានធម្មជាតិផ្សេងទៀត ហេតុអ្វីបានជាយើងនៅតែស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតនិងជាប្រទេសកំពុងអភិវឌ្ឍ?" ចំណុចនេះរំឭកយើងអំពីការវិភាគរបស់សាស្ត្រាចារ្យ ផូល ខូលីយេ (Paul Collier)អំពីមូលហេតុដែលប្រជាជនមួយពាន់លាននាក់ជុំវិញពិភពលោក បានជាប់គាំងនៅបាតក្រោមនៃការអភិវឌ្ឍបានន័យថាពួកគេមាន

[១] ណារ៉ា សុខហេម៉ា គឺជានិស្សិតបញ្ចប់ថ្នាក់អនុបណ្ឌិតនៃដេប៉ាតឺម៉ង់សិក្សាអន្តរជាតិនៃវិទ្យាស្ថានភាសាបរទេស សកលវិទ្យាល័យភូមិន្ទភ្នំពេញ និង និស្សិតបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចពីសកលវិទ្យាល័យកម្ពុជា។ អត្ថបទនេះត្រូវបានដកស្រង់ពីអត្ថបទតែងសេចក្តីទាំងស្រុងមួយ ដែលបានទទួលរង្វាន់លេខមួយក្នុងការប្រកួតប្រជែងសរសេរអត្ថបទស្តីពីឧស្សាហកម្មនិស្សារណកម្មនៃអង្គការអុកស្វាមអាមេរិក ក្នុងខែឧសភា ឆ្នាំ២០១៣។

ការលូតលាស់រីកចំរើនយ៉ាងយឺត ឬមិនរីកចំរើនទាល់តែសោះឬដល់ថ្នាក់ដើរថយក្រោយថែមទៀតផង។ ជាការគួរឲ្យសោកស្តាយ ប្រទេសកម្ពុជាក៏ត្រូវបានរាប់បញ្ចូលទៅក្នុងបញ្ជីនៃ "ប្រជាជនមួយពាន់លាននាក់នៅបាតក្រោម" នេះផងដែរ។

យោងតាមការសិក្សារបស់ ខូលីយេ (ខូលីយេ ឆ្នាំ២០០៧) មានអន្ទាក់បួនដែលអូសទាញប្រទេសកំពុងអភិវឌ្ឍ ឲ្យធ្លាក់ទៅក្នុងបាតក្រោមនៃការអភិវឌ្ឍៈ ១) សង្គ្រាម ឬជម្លោះផ្ទៃក្នុង, ២) ការមិនមានដែនដីជាប់សមុទ្ទ ហើយមានប្រទេសជិតខាងមិនល្អ, ៣) ធនធានធម្មជាតិ, និង ៤) អភិបាលកិច្ចមិនល្អ។ ជាបឋម វិវាទឬសង្គ្រាមស៊ីវិលគឺជាអន្ទាក់ដ៏កាចសាហាវមួយ ដោយសារវាកាត់បន្ថយកំណើនសេដ្ឋកិច្ចចំនួន ២.៣ ភាគរយក្នុងមួយឆ្នាំ។ សង្គ្រាមមានលក្ខណៈអាក្រក់ធ្ងន់ធ្ងរជាងការធ្លាក់ចុះសេដ្ឋកិច្ចរយៈពេលវែងទៅទៀត ដោយសារវាឆក់យកអាយុជីវិតមនុស្សបំផ្លិចបំផ្លាញវប្បធម៌ ហេដ្ឋារចនាសម្ព័ន្ធ និង បង្កើតការភ័យខ្លាចឬភាពរើសអើងក្នុងសង្គម។ ម្យ៉ាងទៀត ការភៀសខ្លួនឬចំណាកស្រុកខ្នាតធំនៃប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ដោយសារសង្គ្រាមបណ្តាលឲ្យមានការធ្លាក់ចុះនៃផលិតភាពសេដ្ឋកិច្ចការកើនឡើងនៃឧក្រិដ្ឋកម្មផលប៉ះពាល់ដល់សុខមាលភាពប្រជាជន និងបញ្ហាធ្ងន់ធ្ងរផ្សេងៗទៀត ដែលប៉ះពាល់ប្រទេសមានសង្គ្រាមផ្ទាល់ហើយថែមទាំងជះឥទ្ធិពលអវិជ្ជមានលើតំបន់ទាំងមូល។

អន្ទាក់ទីពីរ គឺការមិនមានដែនដីជាប់សមុទ្ទហើយមានប្រទេសជិតខាងមិនល្អ។ បើគ្មានដែនដីជាប់សមុទ្ទ ប្រទេសមួយបាត់បង់ឱកាសជាច្រើនសម្រាប់ការនាំចេញ និងការនាំចូលផលិតផល។ ភាពនៅដាច់ឯកោពីពាណិជ្ជកម្ម បណ្តាលឲ្យមានកំណើនសេដ្ឋកិច្ចយឺត ឬគ្មានការរីកចំរើនទាល់តែសោះ។ ភាពគ្មានដែនដីជាប់សមុទ្ទមានលក្ខណៈកាន់តែអាក្រក់ធ្ងន់ធ្ងរ នៅពេលដែលប្រទេសនោះមានព្រំដែនជាប់ប្រទេសជិតខាងក្រីក្រ ដែលមានហេដ្ឋារចនាសម្ព័ន្ធនិងសេដ្ឋកិច្ចអន់ថយ ដែលជាហេតុធ្វើឲ្យប្រទេសនោះមិនមានទីផ្សារល្អ ដើម្បីទិញយកផលិតផលនាំចេញរបស់ខ្លួន ឬ ដើម្បីផ្គត់ផ្គង់ផលិតផលដែលខ្លួនត្រូវការ ហើយម្យ៉ាងទៀតប្រទេសជិតខាងទាំងនេះ ក៏មិនអាចធ្វើជាច្រកទ្វារដើម្បីបើកផ្លូវទៅរកទីផ្សារផ្សេងៗនៅឯនាយសមុទ្ទផងដែរ។ ក្រៅពីនេះ លទ្ធភាពកំនើនសេដ្ឋកិច្ចដែលទទួលបានពីឥទ្ធិពលសេដ្ឋកិច្ចរីកចម្រើននៃប្រទេសជិតខាងក៏មានលក្ខណៈទាបផងដែរ។

ទីបី ធនធានធម្មជាតិអាចគឺជាពរជ័យសំរាប់ប្រទេសដូចករណីនៃប្រទេសណ័រវ៉េ ឬវាអាចជាបណ្តាសាមួយ ដូចករណីនៃប្រទេសនីហ្សេរីយ៉ា អាស្រ័យលើការគ្រប់គ្រងរបស់ប្រទេសនីមួយៗ។ ប្រជាជនមួយពាន់លាន់នាក់នៅបាតក្រោម គឺជាប្រជាជន ដែលទទួលរងបណ្តាសាពីធនធានធម្មជាតិ។ ក្នុងវិស័យសេដ្ឋកិច្ច ការដកយកធនធាន និងការធ្វើអាជីវកម្មរ៉ែច្រើនពេក និងឆាប់រហ័សពេក អាចបណ្តាលអោយប្រទេសជួបប្រទះបញ្ហា "ជម្ងឺហូឡង់ដ៍" ដែលបណ្តាលឲ្យរូបិយប័ណ្ណឡើងថ្លៃខ្លាំង ឯផលិតភាព និងគំនិតច្នៃប្រឌិតបែរជាធ្លាក់ចុះដោយសារមានការពឹងផ្អែកជ្រុលទៅលើប្រាក់ចំណូលពីធនធានធម្មជាតិ ដែលជាធនធានមិនកកើតឡើងវិញទាំងនោះ។ ក្នុងវិស័យនយោបាយធនធានធម្មជាតិ អាចធ្វើឲ្យលទ្ធិប្រជាធិបតេយ្យមានភាពអន់ថយ ពីព្រោះថាជំនួសឲ្យការខិតខំផ្តល់សេវាសាធារណៈល្អដល់ប្រជាជន ដើម្បីទទួលបានប្រជាប្រិយភាព រដ្ឋាភិបាលគ្រាន់តែប្រើប្រាស់ប្រាក់ ដែលបានមកយ៉ាងងាយស្រួលពីការលក់ធនធានធម្មជាតិ ដើម្បីទិញសន្លឹកឆ្នោតពីប្រជាពលរដ្ឋ។ លើសពីនេះទៀត រដ្ឋាភិបាល មិនចាំបាច់ពឹងផ្អែកលើប្រាក់ចំណូលពន្ធទេ ហេតុនេះប្រជាពលរដ្ឋ ក៏មិនសូវចាប់អារម្មណ៍ពីការប្រើប្រាស់ថវិការដ្ឋ ឬមិនសូវមានឥទ្ធិពលក្នុងការដាក់សម្ពាធ ឲ្យរដ្ឋាភិបាលមានតម្លាភាពនិងគណនេយ្យភាពនោះដែរ។ ជួនកាលប្រាក់ចំណូលពីធនធានធម្មជាតិ អាចក្លាយជាប្រភពទ្រទ្រង់រដ្ឋាភិបាលពុករលួយអោយ នៅតែបន្តកាន់អំណាច ឬជួនកាលវាអាចក្លាយជាប្រភពហិរញ្ញវត្ថុសំរាប់ឲ្យភាគីជម្លោះ បង្កសង្គ្រាមទៀតផង។ ក្នុងផ្នែកបរិស្ថាន ការធ្វើអាជីវកម្មលើធនធានធម្មជាតិអាចនាំឲ្យមានការរិចរិលដីការបំពុលទឹកកង្វក់ខ្យល់ គ្រោះមហន្តរាយបរិស្ថាននានា ដូចជាការរញ្ជួយដី ការបាក់ដី ទឹកជំនន់ បម្រែបម្រួលអាកាសធាតុ ក៏ដូចជាផលប៉ះពាល់អវិជ្ជមានលើសុខភាពមនុស្ស ដែលធ្វើឲ្យពួកគេបាត់បង់ផលិតភាពនិងអាយុជីវិត។

អន្ទាក់មួយទៀត គឺអភិបាលកិច្ចមិនល្អ។ ក្នុងវិស័យនយោបាយ អភិបាលកិច្ចមិនល្អអាចត្រូវបានគេសង្កេតឃើញ ក្រោមរូបភាពនៃអំពើពុករលួយ

វិសមភាពក្នុងសង្គម សម្ពាធនយោបាយពីសំណាក់រដ្ឋាភិបាល និងកង្វះសេរីភាពគណនេយ្យភាព តម្លាភាព និងទំនុកចិត្តពីប្រជាពលរដ្ឋ។ ក្នុងវិស័យសេដ្ឋកិច្ច អភិបាលកិច្ចមិនល្អអាចអូសទាញឲ្យសេដ្ឋកិច្ច និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ធ្លាក់ចុះ ព្រោះថាអភិបាលកិច្ចមិនល្អ ជាកត្តារំខានដល់ការវិនិយោគទុន និងកាត់បន្ថយប្រសិទ្ធភាពនៃចំណាយថវិការដ្ឋ។

## ចំណែកកម្ពុជាយើងវិញ? តើយើងមានជាប់អន្ទាក់ណាខ្លះ? តើត្រូវធ្វើដូចម្តេចដើម្បីរួចផុតពីអន្ទាក់ទាំងនេះ?

ជាបឋម ប្រទេសកម្ពុជាធ្លាប់ជាប់អន្ទាក់សង្គ្រាមអស់រយៈពេលជាង ២-៣ ទសវត្សរ៍ (ចុងទសវត្សរ៍ ១៩៦០ - ទសវត្សរ៍ ២000) ហើយជាកុសល យើងបានឆ្លងផុតអន្ទាក់មួយនេះដោយសារការរួមចំណែកមួយភាគពីសហគមន៍អន្តរជាតិដែលបានផ្តល់ជំនួយ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ) អន្តរាគមន៍ (អ៊ុនតាក់ និងស្ថាប័នផ្សេងទៀត)ជំនួយផ្នែកច្បាប់ និងគោលនយោបាយពាណិជ្ជកម្មដែលជាចំណែកជួយឲ្យយើងដោះស្រាយបញ្ហាក្រោយសង្គ្រាមនានា ដូចជាការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ការដោះមីន ការកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ការស្តារនីតិសម្បទាអភិបាលកិច្ចការបង្កើតច្បាប់ ។ល។និង។ល។ ទោះបីជាប្រទេសកម្ពុជាហាក់បីដូចជាងើបផុតពីអន្ទាក់នេះក្តីប្រទេសយើងក៏នៅមានកង្វល់អំពីវិវាទមួយចំនួនទាក់ទិននឹងវិសមភាពក្នុងសង្គម ជាពិសេស នៅក្នុងបញ្ហាដីធ្លី/សិទ្ធិមនុស្ស ដែលធ្វើឲ្យប្រជាពលរដ្ឋក្រីក្រមួយចំនួនរងទុក្ខវេទនា ហើយបង្កឱកាសឲ្យរឿងនេះក្លាយជាបញ្ហាដ៏ក្តៅមួយ សម្រាប់ការប្រកួតប្រជែងនយោបាយ។

ទីពីរ ប្រទេសកម្ពុជាមិនមែនជាប្រទេសគ្មានដែនដីជាប់សមុទ្រទេ។ ប៉ុន្តែ ការនាំចេញរបស់យើងនៅមិនទាន់មានលក្ខណៈខ្លាំងក្លានៅឡើយ ដោយសារវិស័យដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធរបស់យើងនៅមានកម្រិតក្នុងការនាំចេញធន់ធ្ងន់រឺខ្នាតធំសំរាប់ប្រទេសយើង ឬមិនមានលទ្ធភាពធ្វើឲ្យប្រទេសយើងក្លាយជាច្រកនាំចេញ ដ៏ល្អមួយសម្រាប់ប្រទេសជិតខាងយើង ជាពិសេសប្រទេសឡាវដែលគ្មានដែនដីជាប់សមុទ្ទ ក្នុងការពឹងពាក់កម្ពុជាជាច្រកទ្វារសម្រាប់ធ្វើការនាំចេញរបស់គេ។ អាស្រ័យហេតុនេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងសមធម៌ចាំបាច់ត្រូវស្ថិតនៅក្នុងបញ្ជីអាទិភាពរបស់យើង។

ទីបី ក្នុងផ្នែកធនធានធម្មជាតិប្រទេសកម្ពុជាបានធ្វើអាជីវកម្មរ៉ែខ្លះ ប៉ុន្តែនៅមិនទាន់បានធ្វើអាជីវកម្មពេញលេញនៅឡើយទេ។ ប្រការដែលកំណត់ថា តើយើងនឹងធ្លាក់ចូលក្នុងអន្ទាក់ធនធានឬទេនោះ គឺជាប្រធានបទដ៏សំខាន់មួយដែលត្រូវពិចារណាយ៉ាងមធ្យ័តចាប់ពីពេលនេះតទៅ។ មកដល់ពេលនេះ គេឃើញមានសញ្ញាអវិជ្ជមានខ្លះ ឧទាហរណ៍ ក្រុមហ៊ុនជាច្រើន ជាពិសេសក្រុមហ៊ុនមកពីប្រទេសចិន បានទទួលសម្បទានដីសេដ្ឋកិច្ចដើម្បីប្រើប្រាស់ដីរបស់យើង (UNHCR, ឆ្នាំ ២០០៧) ប៉ុន្តែ គេឃើញមានការចោទប្រកាន់មួយចំនួនថាក្រុមហ៊ុនទាំងនេះជាក់ស្តែងបានកេងប្រវ័ញ្ចធនធានធម្មជាតិដោយកាប់ព្រៃឈើ ហើយដាំដំណាំដែលមានគុណតម្លៃទាបជំនួសវិញ (ស៊ីផាត ឆ្នាំ ២០០៨, ខែសីហា ឆ្នាំ ២០១១)។ ក្នុងករណីខ្លះ ក្រុមហ៊ុនទាំងនោះបានយកដីដែលត្រួតស៊ីគ្នានឹងដីប្រជាពលរដ្ឋក្រីក្រ ដែលនាំឲ្យមានវិសមភាពនិងទុក្ខវេទនាចំពោះពួកគេ (CHRAC, ឆ្នាំ ២០១០)។ អនុសាសន៍មួយចំនួន រួមមានជាអាទ៏គឺ ច្បាប់ភូមិបាលត្រឹមត្រូវ ច្បាប់ស្តីពីធនធានធម្មជាតិ ច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និង កម្មវិធីតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)។ ជាមួយនឹងប្រាក់ចំណូលរំពឹងទុកប្រហែលចំនួន ១.៧ពាន់លានដុល្លាររាល់ឆ្នាំ(PACT,ឆ្នាំ២០០៧) ប្រទេសកម្ពុជាមានឱកាសក្នុងការប្រើប្រាក់ចំណូលនេះ ប្រកបដោយប្រសិទ្ធិភាព ដើម្បីអភិវឌ្ឍវិស័យផ្សេងទៀតជាច្រើន និង ដើម្បីចេញផុតពីភាពក្រីក្រ។ ប៉ុន្តែបើគ្មានការគ្រប់គ្រងត្រឹមត្រូវទេនោះ ប្រទេសកម្ពុជានឹងនៅតែក្រ ហើយព្រមទាំងប្រឈមមុខនឹងបណ្តាសាធនធាន។ ម្យ៉ាងទៀតឧស្សាហកម្មនិស្សារណកម្មចាំបាច់ ត្រូវមានតម្លាភាពនៅក្នុងគ្រប់ដំណាក់កាលទាំងអស់ ដូចជាការដេញថ្លៃដោយបើកចំហរជាសាធារណៈ និងប្រកបដោយយុត្តិធម៌ក្នុងការប្រកួតប្រជែងយកអាជ្ញាប័ណ្ណ និងការធ្វើកិច្ចសន្យាការផ្តល់ព័ត៌មានសមស្របទាក់ទងទៅនឹងនីតិវិធីក្នុងការធ្វើនិយ័តកម្មធនធានធម្មជាតិ ឬ យន្តការតាមដានសកម្មភាពផលិតកម្មនីមួយៗ ចំនួនប្រាក់ពន្ធ ដែលប្រមូលបានការផ្សព្វផ្សាយ

អំពីប្រាក់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម និងបញ្ជីលម្អិតនៃចំណាយនៃប្រាក់ចំណូល។ ការមានតម្លាភាពបែបនេះ មានសារៈសំខាន់ណាស់ ដើម្បីកាត់បន្ថយអំពើពុករលួយ នៅក្នុងដំណាក់កាលនីមួយៗនៃវិស័យឧស្សាហកម្មនិស្សារណកម្ម និង ដើម្បីធានាឲ្យបានថាប្រាក់ចំណូលទាំងនេះ ត្រូវបានប្រើប្រាស់យ៉ាងសមស្រប និងប្រកបដោយសមភាពដើម្បីអភិវឌ្ឍប្រទេសយ៉ាងពិតប្រាកដ។

កម្ពុជា ក៏មានបញ្ហាជាមួយអន្ទាក់អភិបាលកិច្ចមិនល្អផងដែរ។ កម្ពុជាជាប់ចំណាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសពុករលួយបំផុតក្នុងពិភពលោក យោងតាមសន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយ (Corruption Perception Index) ដែលនៅក្នុងនោះ យើងទទួលបានពិន្ទុ ២២/១០០ និង ចំណាត់ថ្នាក់ទី១៥៧ ក្នុងចំណោម ១៧៦ ប្រទេស (អង្គការតម្លាភាពអន្តរជាតិឆ្នាំ២០១២)។ ក្រៅពីនេះ សិទ្ធិនិងសេរីភាពនៃការបញ្ចេញមតិ សារព័ត៌មាន ការផ្សព្វផ្សាយ និងការប្រមូលផ្តុំដែលត្រូវបានអនុញ្ញាតដោយរដ្ឋធម្មនុញ្ញយើង នៅតែទទួលរងសម្ពាធ ដូច្នេះប្រជាពលរដ្ឋនៅតែមិនទាន់ទទួលបានអំណាចពេញលេញ ដូចដែលពួកគេ គួរទទួលបាននៅក្នុងរបបប្រជាធិបតេយ្យដ៏ពេញលេញមួយ។ប្រទេសយើងបានចុះហត្ថលេខា និង ផ្តល់សច្ចាប័នទៅលើអនុសញ្ញាអន្តរជាតិមួយចំនួនស្តីពីសិទ្ធិមនុស្ស និងការប្រឆាំងនឹងអំពើពុករលួយ ប៉ុន្តែ យើងនៅមិនទាន់បានអនុវត្តអនុសញ្ញាទាំងនេះឲ្យបានពេញលេញនៅឡើយ។ ទោះជាយ៉ាងណាក្តី ប្រការនេះមិនមែនមានន័យថាកម្ពុជាគ្មានសង្ឃឹមសោះ និងត្រូវអន្តរាយនៅក្នុងអន្ទាក់នេះទេ ព្រោះថាយើងនៅមានឱកាសអាចកែលម្អបាន។ ការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ គឺជាកត្តាស្នូលដើម្បីលើកស្ទួយប្រទេសជាតិយើង។ អ្វីដែលច្បាប់និងកិច្ចអន្តរាគមន៍អន្តរជាតិអាចជួយបាន គឺការផ្តល់ក្របខ័ណ្ឌគោលនយោបាយ និង ជំនួយ (ទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ) ក៏ដូចជាការដាក់គំនាបពីសំណាក់អន្តរជាតិ ដើម្បីឲ្យប្រទេសយើងអនុវត្តច្បាប់នានា ដើម្បីធ្វើឲ្យអភិបាលកិច្ចប្រទេសយើងកាន់តែប្រសើរឡើង មានតម្លាភាព គណនេយ្យភាព និង យុត្តិធម៌ប្រសើរជាងមុន។

## ក្នុងនាមជាប្រជាពលរដ្ឋនិងយុវជន យើងអាចជួយធ្វើឲ្យមានភាពប្រសើរឡើង!

ប្រជាពលរដ្ឋ និងយុជនមានអំណាចខ្លាំងណាស់ប៉ុន្តែ យើងមិនបានដឹងនូវអ្វីទាំងអស់ដែលយើងគួរតែដឹង ដោយសារសាលារៀនមិនអាចបង្រៀនយើងគ្រប់រឿងបានទេ ម្យ៉ាងយើងមិនសូវមានវប្បធម៌នៃការសិក្សាស្រាវជ្រាវដោយឯករាជ្យទេ រីដោយសារកង្វះសិទ្ធិទទួលបានព័ត៌មាន។តាមពិតយើងអាចចូលរួមចំនែកដំណោះស្រាយបញ្ហាតាមមធ្យោបាយជាច្រើន។ទីមួយ យើងគប្បីស្វែងរកការយល់ដឹងនិងចំណេះថែមទៀតដោយខ្លួនឯងជំនួសឲ្យការនៅស្ងៀមដោយរង់ចាំតែគេផ្តល់ព័ត៌មានឲ្យ។ តាមរយៈការស្រឡាញ់ការអាន ការស្រាវជ្រាវ និងការពង្រីកចំណេះដឹងរបស់យើង យើងអាចគោងឡើងផុតជញ្ជាំងដែលហ៊ុំព័ទ្ធយើង ហើយពេលនោះយើងអាចមើលឃើញ បានកាន់តែទូលាយអំពីអ្វីដែលបាននឹងកំពុងកើតឡើងជាក់ស្តែង នៅក្នុងប្រទេសយើងក្នុងខណៈ ដែលយើងមិនបានកត់សម្គាល់។

ទីពីរ យើងត្រូវបង្ហាញការយល់ដឹងជំនួសឲ្យការគ្រាន់តែដឹងប៉ុន្តែនៅស្ងៀម ឬធ្វើពុតជាមិនដឹងអ្វីទាំងអស់។ ការយល់ដឹងរបស់យើងគឺការបង្ហាញទៅមេដឹកនាំថា យើងទាមទារឲ្យពួកគេកែលម្អកាន់តែប្រសើរពីព្រោះយើងមិនមែនគ្រាន់តែជាប្រជាពលរដ្ឋល្ងីតល្ងង់ ដែលពួកគេអាចត្រួតត្រាដោយមិនចាំបាច់ផ្តល់សេវាសមស្រប ដែលយើងគប្បីទទួលបានបន្ទាប់ពីយើងបានផ្តល់សន្លឹកឆ្នោតឲ្យពួកគេនៅក្នុងពេលបោះឆ្នោតកន្លងមកនោះទេ។ ក្នុងនាមជាប្រជាពលរដ្ឋពួកយើង មានសិទ្ធិដឹងនិងចោទសួរទៅលើបញ្ហាទាំងនេះ។

ទីបី យើងចាំបាច់ត្រូវធានាឲ្យបានប្រាកដថា ក្នុងនាមយើងជាយុវជនយើងបានត្រៀមខ្លួនរួចរាល់ដើម្បីចូលរួមក្នុងការដោះស្រាយបញ្ហា។ យើងគប្បីចាប់ផ្តើមសម្រួចចំណេះដឹងរបស់យើង ដើម្បីបំពេញកំណើនតម្រូវការកម្លាំងពលកម្ម ជំនាញអ្នកបច្ចេកទេស និងវិស្វករ ដើម្បីធ្វើអាជីវកម្មប្រេងកាតនិងធនធានធម្មជាតិផ្សេងទៀត។ ការសិក្សា/ធ្វើការនៅបរទេសមួយរយៈ ដើម្បីស្រូបយកជំនាញដែលប្រទេសយើងមិនទាន់មានគឺជាការល្អ ដែលអាចទទួលយកបាន ប៉ុន្តែ យើងត្រូវតែជៀសវាងការស្រូបខួរក្បាលពីសំណាក់ប្រទេសផ្សេង (ពោលគឺមិនគួររស់នៅក្រៅប្រទេស បន្ទាប់ពីការបញ្ចប់ការសិក្សាដោយមិនយកជំនាញ ដែលប្រមូលបានមកបំរើប្រទេសកំនើតវិញ)។ ម្យ៉ាងទៀត ពួកយើងគប្បីប្រកាន់យកគោលការណ៍សុចរិតភាព ទោះបីជាយើងធ្វើអ្វី និងធ្វើការនៅទីណាក៏ដោយ ហើយត្រូវ

ត្រៀមខ្លួនជាស្រេច ដើម្បីបម្រើដើម្បីភាពឲ្យល្អប្រសើរឡើង។

ទីបួន យើងមិនគួរយល់ថាការកែប្រែជាវិជ្ជមានក្នុងសង្គម ឬការដឹកនាំចេញមកតែពីមេដឹកនាំនោះទេ ព្រោះថា ក្នុងនាមជាប្រជាពលរដ្ឋ យើងអាចធ្វើការកែប្រែនិងដឹកនាំការកែលម្អសង្គមរបស់យើងតាមរយៈការចែករំលែកចំណោះដឹងជូនប្រជាពលរដ្ឋដទៃដែលមិនទាន់បានដឹង ឬមិនបានចូលរួមក្នុងការសម្រេចចិត្តសង្គម។ ឧទាហរណ៍មួយចំនួនគឺរៀបចំការប្រជុំ វិវគ្គចែករំលែកតូចៗនៅសាលាការផ្តួចផ្តើមក្លឹបអាន ការរៀបចំព្រឹត្តិការណ៍នានា (ដូចជា សិក្ខាសាលា សន្និសីទ ការពិភាក្សាតុមូល ។ល។) ដើម្បីអញ្ជើញវាគ្មិនពីស្ថាប័នផ្សេងៗឲ្យមកចែករំលែកចំណោះដឹង និងបទពិសោធន៍ពួកគេការធ្វើយុទ្ធនាការ ដើម្បីលើកស្ទួយសម្លេងនិងការទាមទាររួមរបស់ប្រជាជន ការផ្តួចផ្តើមគម្រោងតូចៗ ឬការស្ម័គ្រចិត្តធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬ ស្ថាប័នណាមួយ ដើម្បីរៀនសូត្រជំនាញសំខាន់ៗ និងដើម្បីទទួលបានបទពិសោធន៍ជាក់ស្តែងអំពីរបៀបតស៊ូមតិ ឬរបៀបបង្កើតនិងគ្រប់គ្រងគម្រោងដើម្បីជួយសហគមន៍។ សម្លេងរបស់យើង គឺសារមួយដែលទាមទារមេដឹកនាំរបស់យើង និងសហគមន៍អន្តរជាតិឲ្យជួយដាក់សម្ពាធដើម្បីឲ្យមានការកែលម្អកាន់តែប្រសើរឡើង។

ម្យ៉ាងទៀត ឥរិយាបថក្នុងការប្រើប្រាស់ផលិតផលរបស់យើង ក៏អាចមានឥទ្ធិពលលើក្រុមហ៊ុនផងដែរ ហើយយើងអាចដាក់បន្ថែមទំងន់នៃការទាមទារ និងសម្ពាធទៅមេដឹកនាំ ដើម្បីពួកគេកែលម្អប្រទេសយើង កាន់តែប្រសើរផងដែរ។ ឧទាហរណ៍ប្រសិនបើក្រុមហ៊ុនមួយស្ទូកប៉ាន់ ដើម្បីទទួលបានការព្រមព្រៀងខុសច្បាប់ ឬលាក់ព័ត៌មានដែលប្រជាពលរដ្ឋ ដូចយើងទាំងអស់គ្នាមានសិទ្ធិដឹង យើងអាចដាក់សម្ពាធលើក្រុមហ៊ុននោះ ដោយបញ្ឈប់ការទិញ ផលិតផលរបស់ក្រុមហ៊ុននោះ ហើយបែរមកប្រើផលិតផលរបស់ក្រុមហ៊ុន ដែលជាគូប្រកួតប្រជែងរបស់គេវិញ។ ប្រសិនបើមនុស្សតែម្នាក់ធ្វើដូច្នេះ នោះវានឹងមិនមានប្រសិទ្ធិភាពទេ។ ប៉ុន្តែ ប្រសិនបើយើងទាំងអស់គ្នារួបរួមគ្នាដាក់សម្ពាធបែបនេះ ក្រុមហ៊ុននោះនឹងមានការភ័យខ្លាចអំពីការខូចស្លាកយីហោ កេរ្តិ៍ឈ្មោះ និងប្រាក់ចំណូលរបស់ខ្លួន ដូច្នោះក្រុមហ៊ុននោះចាប់ផ្តើមផ្លាស់ប្តូររបៀបធ្វើជំនួញរបស់គេ និងបញ្ចុះបញ្ចូលឲ្យរដ្ឋាភិបាលកែលម្អច្បាប់ពាក់ព័ន្ធផងដែរ។

និយាយដោយខ្លី អនាគតស្ថិតនៅក្នុងកណ្តាប់ដៃយើង។ ពោលគឺប្រជាពលរដ្ឋ គប្បីសាមគ្គីគ្នាដើម្បីទាមទារឲ្យមានការកែលម្អ កាន់តែប្រសើរឡើង និងសហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីនាំមកនូវការអភិវឌ្ឍវិជ្ជមានជូនប្រទេសកម្ពុជា។

## ឯកសារយោង

Cambodian Human Rights Action Committee (CHRAC). (2010). Still Losing Ground : Forced Evictions and Intimidation in Cambodia. Phnom Penh: CHRAC.

Collier, P. (2007). The Bottom Billion. New York, USA: Oxford University Press.

Heng Seiha, K. S. (2011). Decentralized Governance in a Hybrid Polity: Localisation of Decentracation in Cambodia.

PACT organization. (2007). Oil and Gas in Cambodia . Phnom Penh: PACT.

Siphat, T. (2008). Degraded Forest as a Discursive Tactic of Economic Land Concessions: A case Study of O Tanoeung Village, Kbal Dam Rey Commune, Kratie Province, Northeastern Cambodia . Changes and Challenges in Greater Mekong Sub-region .

Transparency International. (2012). Transparency International Organization. Retrieved 0505, 2013, from Curruption by Country: http://www.transparency.org/country#KHM

UNHCR. (2007). Land Concession for Economic purposes in Cambodia. A human right perspective. Phnom Penh: United Nations Cambodia Office.

# ការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC)[១] និងការអនុវត្ត នៅក្នុងសហគមន៍ជនជាតិដើមភាគតិច

*អត្ថបទដោយ៖ លោកស្រី សៅ វិច្ឆិកា*
*មន្ត្រីស្រាវជ្រាវនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

ជាង១.៤លាននាក់នៃជនជាតិដើមភាគតិច មកពី២៤ក្រុម កំពុងរស់នៅក្នុងខេត្តចំនួន១៥ ក្នុងស្រុកចំនួន៣៩ ក្នុងឃុំចំនួន៦៨ និងក្នុងភូមិចំនួន ១ ៨ ៦ នៃព្រះរាជាណាចក្រកម្ពុជាមួយនេះ[២] ។ រឿងនេះធម្មតាណាស់ ដែលជនជាតិដើមភាគតិចជាម្ចាស់ស្រុក រស់នៅរាយប៉ាយជាងពាក់កណ្តាលប្រទេស។ ប៉ុន្តែសំនួរសួរថាតើក្រុមមនុស្សទាំងនេះបាននឹងកំពុងសោយសុខនៅលើទឹកដីកំណើតរបស់ពួកគេ ឬទេនៅក្នុងបរិយាកាសសង្គមបច្ចុប្បន្ន ដែលដីសម្បទានសេដ្ឋកិច្ច កំពុងជាចំណុចដ៏សើប និងជាទីចាប់អារម្មណ៍នោះ? ហើយតើក្រុមមនុស្សទាំងនេះយល់ស្របទេ ចំពោះទស្សនទានអភិវឌ្ឍន៍របស់រដ្ឋាភិបាល។

របាយការណ៍ស្រាវជ្រាវមួយ ដែលនិពន្ធដោយ Mark Kavenagh, Dom Renfrey និង Erin Flynn ដែលដាក់ចំណងជើងថា "ការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់(FPIC) ក្នុងដំណើរការអភិវឌ្ឍនៅក្នុងសហគមន៍ជនជាតិដើមភាគតិច នៅក្នុងខេត្តមណ្ឌលគិរីនិងរតនគិរី" និងបានបោះពុម្ពដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា កត់សំគាល់ថា តំបន់ភូមិភាគឦសាននៃប្រទេសកម្ពុជា ដែលមានជនជាតិដើមភាគតិចជាច្រើនបាននឹងកំពុងរស់ នៅកំពុងទទួលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច និងអជ្ជាប័ណ្ណរុករករ៉ែដែលរដ្ឋាភិបាលផ្តល់ទៅឲ្យក្រុមហ៊ុនឯកជន។ ការកត់សំគាល់នេះ ផ្អែកទៅលើករណីសិក្សាចំនួន៤នៅខេត្តមណ្ឌលគិរី និងរតនគិរី ដែលករណីសិក្សាទាំងបួននោះ បានធ្វើឡើងជាមួយសហគមន៍ជនជាតិដើមភាគតិចដើម្បីឆ្លុះបញ្ចាំងនូវបទពិសោធន៍ផ្ទាល់របស់សហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ច និង/ឬអាជ្ញាប័ណ្ណរុករករ៉ែ។ ករណីសិក្សាទាំងបួនបានរកឃើញថា មានករណីមួយចំនួនជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់មិនបានទទួលការពិគ្រោះយោបល់ត្រឹមត្រូវ ក្នុងទំរង់ណាមួយឡើយនៅកំរិតសហគមន៍មូលដ្ឋានខណៈពេល ដែលសហគន៍មួយចំនួនទៀតមិនបានដឹងទាល់តែសោះអំពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច នៅលើដីរបស់ខ្លួន រហូតទាល់តែការឈូសឆាយចាប់ផ្តើម។ ការរកឃើញនេះ មានភាពស៊ីសង្វាក់គ្នាជាមួយការស្រាវជ្រាវ និងឯកសារផ្សេងៗដែលមានស្រាប់នៅប្រទេសកម្ពុជាដែលបានបញ្ជាក់ថា ការពិគ្រោះយោបល់ គឺជាតំរូវការចាំបាច់ដែលមានចែងក្នុងអនុក្រឹត្យស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ កិច្ចពិគ្រោះយោបល់ ត្រូវបានចងក្រងឯកសារដោយភាគីក្រុមហ៊ុន នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ប៉ុន្តែបច្ចុប្បន្នមិនទាន់មាននីតិវិធីច្បាស់លាស់ និងមិនទាន់មានយន្តការគ្រប់គ្រាន់សំរាប់ធ្វើការត្រួតពិនិត្យ ដើម្បីធានាថាក្រុមហ៊ុនបានធ្វើការពិគ្រោះយោបល់យ៉ាងត្រឹមត្រូវគ្រប់កំរិតនៅឡើយទេ។ ជាងនេះទៅទៀតនាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានបានគូសបញ្ជាក់ថារយៈពេល៣០ថ្ងៃសំរាប់ការពិគ្រោះយោបល់ ដ៏ត្រឹមត្រូវជាមួយសហគមន៍នោះ គឺមិនមានពេលគ្រប់គ្រាន់សំរាប់ពួកគាត់ធ្វើការនេះឡើយ។ នេះឆ្លុះបញ្ចាំងថា ព្រះរាជាណាចក្រកម្ពុជា មិនទាន់អនុវត្តនូវគោលការណ៍ FPIC នៅឡើយទេ។

[១] ថ្វីបើប្រទេសកម្ពុជានៅមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញា ILO នេះក៏ដោយ (ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា ILO ចំនួន ៨ ធំៗ) ប៉ុន្តែ ផ្នែកនេះនិយាយជាទូទៅអំពី ទំនាក់ទំនងរវាងច្បាប់អន្តរជាតិដ៏សំខាន់មួយនេះ ជាមួយនឹងសិទ្ធិក្នុងការទទួលបាន FPIC ពោលគឺមិនមែនទៅលើទស្សនៈយល់ឃើញរបស់ ច្បាប់ និងប្រព័ន្ធនយោបាយកម្ពុជា មកលើអនុសញ្ញានេះនោះទេ។ ដូច្នេះ អនុសញ្ញានេះ នៅតែមានលក្ខណៈជាគ្រឹះសម្រាប់ការអនុវត្ត FPIC នៅគ្រប់ទិសទី និងអាចផ្តល់ចំណេះដឹងជាច្រើនសម្រាប់ការស្វែងយល់អំពីមូលដ្ឋានគ្រឹះនៃ FPIC ក្នុងច្បាប់អន្តរជាតិ ជាទូទៅ។
[២] របាយការណ៍ បណ្តាញសកម្មជនជាតិដើមភាគតិចឆ្នាំ២០១២

## អ្វីទៅជាការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC)?

ការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC) គឺជាទស្សនាទានរស់រវើកមួយ ទទួលស្គាល់សមត្ថកិច្ចស្របច្បាប់របស់ជនជាតិដើមភាគតិច ក្នុងការចូលរួម និងធ្វើការសម្រេចចិត្ត ចំពោះសកម្មភាពផ្សេងៗ ដែលស្នើឡើងដោយអ្នកខាងក្រៅសហគមន៍ហើយដែលអាចធ្វើឲ្យមានផលប៉ះពាល់ដល់វប្បធម៌ ប្រពៃណី ទំនៀបទំលាប់ និងអត្តសញ្ញាណរបស់ពួកគាត់។ ទោះបីជាមិនទាន់មានការឯកភាពគ្នាជាសាកលទៅលើនិយមន័យ (FPIC)ក៏ដោយ ក៏ទស្សនាទាននេះជាមធ្យោបាយមួយដ៏ជាក់លាក់ និងមានសារៈប្រយោជន៍ ដើម្បីធានាឲ្យបាននូវការគោរពសិទ្ធិក្នុងការសម្រេចចិត្តរបស់សហគមន៍ជនជាតិដើមភាគតិច លើដីធ្លីរបស់គាត់ដែរ។

## តើ FPIC ត្រូវបានអនុវត្តយ៉ាងដូចម្តេចនៅកម្ពុជា?

FPIC ពន្យល់ថាប្រជាពលរដ្ឋត្រូវតែទទួលបានព័ត៌មានគ្រប់គ្រាន់ជាមុន អំពីផលប៉ះពាល់ដែលនឹងកើតឡើង មុនពេលធ្វើការសម្រេចចិត្តដោយផ្អែកលើដំណើរការនៃការសម្រេចចិត្តដោយផ្ទាល់របស់ពួកគេ។

មាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ ជាងនេះទៀតយោងតាមមាត្រា៣៥ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"។

ពាក់ព័ន្ធនឹងគោលការណ៍(FPIC) ជនជាតិដើមភាគតិចត្រូវបានផ្តល់សិទ្ធិក្នុងការចូលរួម និងធ្វើការសម្រេចចិត្ត នូវរាល់គម្រោងអភិវឌ្ឍន៍ ដែលនឹងត្រូវកើតឡើងនៅក្នុងតំបន់សហគមន៍របស់ពួកគាត់។ ក្នុងចំណោមករណីសិក្សាទាំងបួន គេរកឃើញថាមានករណីបី ដែលមិនបានផ្តល់សិទ្ធិដល់សហគមន៍មូលដ្ឋានក្នុងការចូលរួម និងធ្វើការសម្រេចចិត្តមុននឹងផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនវិនិយោគ។ បញ្ហាជាចម្បងដែលបានលេចឡើងចំពោះជនជាតិដើមភាគតិច ក៏ដូចជាប្រជាជនកម្ពុជាភាគច្រើននោះគឺ ពួកគាត់មិនមានឯកសារផ្លូវការណាមួយ ដែលបញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិលើដី ដែលពួកគាត់កំពុងរស់នៅនោះឡើយ។ អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច បានកំណត់អំពីវិធីតម្រូវឲ្យសហគមន៍ត្រូវបានទទួលស្គាល់ និងចុះបញ្ជីជានីតិបុគ្គល រួចទើបអាចចុះបញ្ជីដីសហគមន៍របស់ខ្លួនបាន។ ជាងនេះទៅទៀតនីតិវិធីនៃការចុះបញ្ជីមានភាពស្មុគស្មាញ និងចំណាយពេលយូរ។ ជាក់ស្តែងរហូតមកដល់ខែឧសភា ឆ្នាំ២០១៣នេះ មានសហគមន៍ជនជាតិដើមភាគតិចតែប្រាំពីរប៉ុណ្ណោះនៅក្នុងប្រទេសដែលបានចុះបញ្ជីដីសហគមន៍ ខណៈពេលដែលសហគមន៍ផ្សេងទៀត កំពុងដំណើការកំណត់ស្វ័យអត្តសញ្ញាណ និងដំណើការចុះបញ្ជីជានីតិបុគ្គល។ សហគមន៍ទាំងបួននៅក្នុងការសិក្សាស្រាវជ្រាវនេះបានឲ្យដឹងថា មានការផ្តល់ព័ត៌មានតិចតួចបំផុតទាក់ទងទៅនឹងការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬអាជ្ញាប័ណ្ណរុករករ៉ែ នៅក្នុងតំបន់សហគមន៍របស់ពួកគាត់។

## សេចក្តីសន្និដ្ឋាន

ករណីសិក្សាទាំង៤ ដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ស្រាវជ្រាវស្តីអំពីការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC) ក្នុងដំណើរការអភិវឌ្ឍន៍ នៅក្នុងសហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី និងរតនគិរី បង្ហាញថាគោលការណ៍ FPIC មិនទាន់ត្រូវបានគោរពនៅឡើយទេ នៅក្នុងប្រទេសកម្ពុជា។ ដើម្បីឲ្យ «មានព័ត៌គ្រប់គ្រាន់» ឲ្យស្របតាមគោលការណ៍របស់ FPIC សហគមន៍ត្រូវដឹងជាមុនអំពីទំហំ ទីតាំង ផលប្រយោជន៍ ផលប៉ះពាល់ និងវិធានការណ៍បន្ធូរបន្ថយនានា ប៉ុន្តែជាក់ស្តែងមិនមានសហគមន៍ណាមួយ ក្នុងចំណោមសហគមន៍ទាំងបួន ត្រូវបានផ្តល់ព័ត៌មានទាំងនេះឡើយ។ លើសពីនេះបែរជារកឃើញមានការបំភិតបំភ័យ បង្ខិតបង្ខំ ក្នុងទម្រង់ផ្សេងៗដល់សហគមន៍ដើម្បីឲ្យសហគមន៍គោរពតាម ដែលទង្វើនេះផ្ទុយស្រឡះទៅនឹងគោលការណ៍ FPIC។ ប្រសិនបើចំណុចទាំងអស់ខាងលើនេះ មិនត្រូវបានដោះស្រាយទេនោះ ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា នឹងគ្មានថ្ងៃអាចចូលរួមដោយស្មើភាព នៅក្នុងដំណើរការនៃការគ្រប់គ្រងដីធ្លីសហគមន៍របស់ពួកគេឡើយ ហើយជនជាតិដើមភាគតិចដែលជាម្ចាស់ស្រុកទាំងនេះ នឹងមិនអាចសោយសុខនៅលើមាតុភូមិកំណើតរបស់ខ្លួនឡើយ។

# តើទំនប់វារីអគ្គិសនីសំបូរ អាចផ្តល់ផលចំណេញច្រើនជាងផលប៉ះពាល់អវិជ្ជមានឬទេ[១]?

អត្ថបទដោយ៖ លោកស្រី ជា ផល្លីកា
មន្ត្រីសម្របសម្រួលគម្រោងសិទ្ធិសហគមន៍ និងទំនប់វារីអគ្គិសនីនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

អត្ថបទនេះ ត្រូវបានសរសេរឡើងក្នុងគោលបំណង ជូនព័ត៌មានដល់អ្នកដែលចាប់អារម្មណ៍ស្វែងយល់ អំពីបញ្ហាការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅប្រទេសកម្ពុជា ពិសេសតាមដងទន្លេមេនៃទន្លេមេគង្គ។

## ព័ត៌មានទូទៅអំពីទន្លេមេគង្គ និងទំនប់វារីអគ្គិសនីសំបូរ

ទន្លេមេគង្គមានប្រវែង ៤៩០០ គីឡូម៉ែត្រ ហូរកាត់៦ប្រទេសគឺ ចិន ភូមា ថៃ ឡាវ កម្ពុជា និង វៀតណាម ជាទន្លេដែលវែងជាងគេលំដាប់ទី១២និងធំជាងគេលំដាប់ទី២១នៅលើពិភពលោក និង ជាប្រភពផ្តល់ត្រីធំជាងគេនៅលើពិភពលោក។ ប្រជាពលរដ្ឋជាង៥៥លាន ពឹងផ្អែកលើធនធានត្រីនៃទន្លេនេះ៖ ផលចាប់ត្រីមានប្រមាណជាជាង២,៥លានតោនក្នុង១ឆ្នាំដែលមានតម្លៃស្មើនឹង២,៥ពាន់លានដុល្លាស្មើនឹង ១/៤ នៃត្រីទឹកសាបក្នុងពិភពលោក(CNMC&WFC,2007)[២]។៨៦%ដែលស្មើនឹង ១៥៥.០០០ គីឡូម៉ែត្រក្រឡានៃផ្ទៃដីប្រទេសកម្ពុជា គឺតំបន់ទំនាបទន្លេមេគង្គ ហូរកាត់ចាប់ពីខេត្តស្ទឹងត្រែងរហូតដល់ភាគខាងត្បូងនៃខេត្តក្រចេះ មុននឹងបន្តហូរធ្លាក់ចូលក្នុងបឹងទន្លេសាប (CNMC & MIME, 2003)[៣]។




នៅតាមដងទន្លេមេនៃទន្លេមេគង្គក្នុងស្រុកសំបូរ ខេត្តក្រចេះ ជាតំបន់សក្តានុពល សម្រាប់ការសាងសង់ទំនប់វារីអគ្គីសនី ហើយ៧០%នៃថាមពលដែលអាចទទួលបានពីទំនប់ គឺត្រូវលក់ទៅឲ្យប្រទេសថៃ វៀតណាម និងប្រទេសចិន (MRC, SEA Vol.11, 2009)[៤]។

[១] អត្ថបទនេះគឺដកស្រង់ពីរបាយការណ៍ស្រាវជ្រាវរបស់លោកស្រី អេសស្តេឡា អេសស្លូវៀ ក្រោមប្រធានបទ «ការចិញ្ចឹមជីវិតដោយពឹងផ្អែកលើទន្លេមេគង្គ៖ របាយការណ៍ការសិក្សាស្រាវជ្រាវនៅស្រុកសំបូរ» ក្រោមការឧបត្ថម្ភថវិកាពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងជំនួយបច្ចេកទេសពីសម្ព័ន្ធទន្លេកម្ពុជា បានផ្សព្វផ្សាយឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២។

[២] CNMC & World Fish Center, 2007, Influence of Built Structures on Tonle Sap Fisheries – Findings and and Recommendations, CNMC and World Fish Centre, Phnom Penh, Cambodia.

[៣] CNMC & MIME 2003, Hydropower, Mekong River Commission and Cambodia National MekongCommittee.

[៤] MRC, SEA Vol.11, 2009. Hydropower on the Mekong Mainstream Inception Report: Mainstream Project Profile Summaries.)

| ការពណ៌នា | គំនូសប្លង់បច្ចុប្បន្ន | ទិន្នន័យរបស់គណៈកម្មការទន្លេមេគង្គ(១៩៩៤) |
|---|---|---|
| ឈ្មោះទំនប់ | សំបូរ | |
| កំពស់ទំនប់ | ៥៦ ម៉ែត្រ | ៣៥ ម៉ែត្រ |
| ប្រវែងទំនប់ | ១៨.០០២ ម៉ែត្រ | ៣០.៦៦៤ ម៉ែត្រ |
| កំលាំងថាមពលសរុប | ២.៦០០ មេហ្គាវ៉ាត់ | ៣.៣០០ មេហ្គាវ៉ាត់ |
| ថាមពលប្រចាំឆ្នាំជាមធ្យម | ១១.៧៤០ Gwh | ១៤.៧៨០ Gwh |
| តំបន់អាងស្តុកទឹក | ៦២០ គីឡូម៉ែត្រការេ | |
| ទំហំជណ្តើរត្រីឆ្លងកាត់ | ៣.៣៦៩,៨ ម៉ែត្រ | |
| រយៈពេលសាងសង់ | ៨៧ ខែ | |
| រយៈពេលនៃកិច្ចសន្យា (BoT[៥]) | ២៥ ឆ្នាំ | |

*ប្រភព: CNMC ២០០៩[៦]*

ទោះជាទំនប់វារីអគ្គិសនីខ្នាតធំតាមដងទន្លេមេនៃទន្លេមេគង្គ អាចផ្តល់សក្តានុពលក្នុងការផលិតថាមពល ប៉ុន្តែវាផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងសង្គម ដូចជាសហាគមន៍រស់នៅជិតតំបន់ទំនប់វារីអគ្គីសនី និងតំបន់ស្តុកទឹក សហាគមន៍រស់នៅក្រោមទំនប់នឹងត្រូវផ្លាស់ប្តូរទីលំនៅ បញ្ហាលើសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ បញ្ហាព្រៃឈើ ធនធានជលផល និងបញ្ហាកសិកម្មនៅតំបន់នោះ។ នេះដោយសារតែទំនប់នេះគ្រោងសាងសង់នៅតំបន់ទំនាបនៃតំបន់ទន្លេមេគង្គ និងថែមទាំងអាចប៉ះពាល់ទៅដល់តំបន់បឹងទន្លេសាបទៀតផង (ផែនទីទំនប់ខាងក្រោមបង្ហាញ ពីភាពទំនាក់ទំនងរវាងប្រព័ន្ធទន្លេមេគង្គ និងទន្លេសាប)។

## របកគំហើញពីការស្រាវជ្រាវលើទំនប់វារីអគ្គិសនីសំបូរ

យោងតាមការសិក្សារបស់លោកស្រី អេស ស្តេឡា អេសស្តូវៀ ក្នុងកំឡុងឆ្នាំ ២០០៩-២០១០ នៅភូមិគោលដៅចំនួន៦ នៃឃុំចំនួន៣ (ភូមិយាវ ភូមិសំភិន និងភូមិកោះដ្តៅ ក្នុងឃុំកំពង់ចាម ភូមិកោះសំ ក្នុងឃុំសំបូរ ភូមិតំរ៉ែក្នុងឃុំបឹងចារ និងភូមិខ្សាច់លាវក្នុងឃុំអូរគ្រៀង) ដែលនឹងទទួលរងនូវផលប៉ះពាល់ ដោយគម្រោងទំនប់វារីអគ្គិសនីសំបូរ ខេត្តក្រចេះ តាមវិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណ និងគុណភាពបានបង្ហាញថា៖

- ទំនប់វារីអគ្គិសនីសំបូរ អាចនឹងជន់លិចផ្ទៃដីទំហំប្រហែល ៦២០ គីឡូម៉ែត្រការ៉េ ដែលជន់លិចអាគាររដ្ឋាភិបាល មន្ទីរពេទ្យ វត្តផ្លូវថ្នល់ គេហដ្ឋាន វាលស្រែ និងប្រព័ន្ធស្រោចស្រព។ ការខូចខាតបែបនេះអាចមានផលប៉ះពាល់ដល់ផ្នែក សង្គមធ្ងន់ធ្ងរជាពិសេស កង្វះសេវាសង្គមកិច្ចមូលដ្ឋាននៅក្នុងស្រុកនេះ។ ម្យ៉ាងទៀត គម្រោងអភិវឌ្ឍន៍ជាច្រើន ដែលត្រូវបានវិនិយោគនៅក្នុងភូមិរងផលប៉ះពាល់ និងជាទូទៅក្នុងស្រុកសំបូរទំនងជាត្រូវបាត់បង់ ដោយសារការជន់លិចនេះ។

[៥] BOT referred to Build Operate and Transfer.

[៦] CNMC 2009, Key SEA Framing Issues: Power demand and power trade development in the LMB and GMS Presentation

- ការធ្វើស្រែ របរនេសាទ ការដាំបន្លែតាមដងទន្លេនិងការងារពលកម្មរកកម្រៃតាមរដូវស្របតាមលំហូរទឹករដូវកាលទន្លេមេគង្គ និង ធនធានផ្សេងៗក្នុងទឹកនៃទន្លេ គឺមានទំនាក់ទំនងខ្លាំងជាមួយគ្នា។ ហេតុដូច្នេះ ការបង្អាក់ណាមួយចំពោះទន្លេមេគង្គ មុខជាធ្វើឲ្យប្រជាជនក្នុងមូលដ្ឋានប្រឈមមុខនឹងស្ថានភាពនានា ដែលនឹងធ្វើឲ្យពួកគេកាន់តែក្រីក្រថែមទៀត និងបង្កើនភាពងាយរងគ្រោះរបស់ពួកគេចំពោះហានិភ័យជាច្រើន ដូចជាបញ្ហាសុខភាព ការបាត់បង់ប្រាក់ចំណូល និងកង្វះអាហារូបត្ថម្ភ។
- ហេតុប៉ះពាល់សំខាន់មួយគឺថា ទំនប់ទំនងជានឹងនាំទៅដល់ការថយចុះបរិមាណមច្ឆាជាតិដែលជាប្រភពដ៏សំខាន់មួយនៃស្បៀងអាហារ និង ប្រាក់ចំណូលសម្រាប់សហគមន៍ជាច្រើននៅក្នុងតំបន់នេះ។ ប្រជាពលរដ្ឋភាគច្រើននៅក្នុងតំបន់នេះ បាននិយាយថាពួកគាត់នេសាទរាល់ថ្ងៃ យ៉ាងហោចណាស់ពី២ទៅ៣ម៉ោងដែរក្នុងមួយថ្ងៃ ហើយក្នុងរយៈពេល៧ខែក្នុងមួយឆ្នាំ ។
- គម្រោងសាងសង់ទំនប់វារីអគ្គិសនីសំបូរបណ្តាលឲ្យអ្នកភូមិព្រួយបារម្ភអំពីអនាគតរបស់ពួកគាត់។ កង្វល់ធំបំផុតដែលពួកគាត់បានលើកឡើងគឺការភ័យខ្លាចនិងសក្តានុពលផលប៉ះពាល់អវិជ្ជមាន ដូចជាការបាត់បង់ជីវភាព ការផ្លាស់ប្តូរលំនៅដ្ឋាន និងការចាកឆ្ងាយពីព្រៃឈើ និងទន្លេ។ កង្វះព័ត៌មានច្បាស់លាស់អំពីស្ថានភាពនៃគម្រោងបានធ្វើឲ្យការភ័យខ្លាចនេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរ។

## អនុសាសន៍ពីការស្រាវជ្រាវ

ដោយសារមានការព្រួយបារម្ភ ក៏ដូចជាផលប៉ះពាល់យ៉ាងធំធេងនេះ អ្នកស្រាវជ្រាវរូបនេះបាន ផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនសំរាប់អង្គការសង្គមស៊ីវិល ដែលធ្វើការទាក់ទងនឹងទន្លេ និង ជីវភាពប្រជាពលរដ្ឋដែលពឹងផ្អែកលើទន្លេមេគង្គ និងទន្លេសាបដូចខាងក្រោមៈ

- គប្បីបង្ហាញជាបន្ទាន់នូវព័ត៌មានច្បាស់លាស់ជូនដល់សហគមន៍មូលដ្ឋានពីស្ថានភាពនៃគម្រោងសាងសង់ទំនប់វារីអគ្គិសនីសំបូរ ដើម្បីសម្រាលការភ័យខ្លាច និងភាពមិនប្រាកដប្រជា ដែលប្រជាជនកំពុងតែបារម្ភអំពីគម្រោង។
- គប្បីសហការជាមួយសហគមន៍មូលដ្ឋានធ្វើការតស៊ូមតិទៅដល់រាជរដ្ឋាភិបាលដើម្បីកែលម្អការទទួលបានព័ត៌មាន និងរៀបចំការពិគ្រោះយោបល់សាធារណៈ ដោយមានការចូលរួមពីសហគមន៍ក្នុងកិច្ចដំណើរការធ្វើការសម្រេចចិត្តអំពីទំនប់នេះ ។
- ធ្វើការរួមគ្នាជាមួយក្រុមក្នុងតំបន់និងអន្តរជាតិដូចជាសម្ព័ន្ធការពារទន្លេមេគង្គ (Save the Mekong Coalition) ដើម្បីធ្វើការងារតស៊ូមតិក្នុងតំបន់ និងអន្តរជាតិស្តីពីទំនប់វារីអគ្គិសនីសំបូរ។
- ផ្សព្វផ្សាយដល់អាជ្ញាធរមូលដ្ឋាន អំពីស្តង់ដារនៃគណៈកម្មការពិភពលោកស្តីពីទំនប់ (World Commission on Dams) និងធ្វើយុទ្ធនាការ ដើម្បីជម្រុញឲ្យពួកគេគោរពតាមស្តង់ដារទាំងនេះ។
- ផ្តួចផ្តើមកិច្ចដំណើរការពិគ្រោះយោបល់ផ្លូវការមួយជាមួយអាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដើម្បីកែលម្អការទទួលព័ត៌មាន និងដើម្បីជម្រុញឲ្យមានការពិគ្រោះយោបល់ដោយមានការចូលរួមរបស់សហគមន៍មូលដ្ឋាន។

ជាសន្និដ្ឋាន ប្រសិនបើទំនប់វារីអគ្គិសនីសំបូរត្រូវបានសាងសង់ នោះនឹងនាំឲ្យប្រទេសកម្ពុជា មានការបាត់បង់សក្តានុពលនៅក្នុងការអភិវឌ្ឍន៍ ព្រមទាំងការបំផ្លាញបរិស្ថាន និងជីវសាស្ត្រ ដោយមិនអាចវិលមករកភាពដើមវិញបាន។ ដូចនេះ ការបាត់បង់ទាំងអស់នេះ គឺមិនអាចកាត់ថ្លៃបាន និងមិនអាចដោះដូរដោយសំណងនោះទេ។